ASSOCIATION OF KHMER ROUGE VICTIMS IN CAMBODIA

# សមាគមជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅកម្ពុជា

…នៅពេលខ្ញុំក្លាយជាក្មេងកំព្រា ខ្ញុំតែងតែគិតថា “តើវាសនាបងរបស់ខ្ញុំ ប្អូនស្រីជាទីស្រលាញ់របស់ខ្ញុំ និង មនុស្សជាទីគោរព ជាទីកក់ក្តៅ និង ជាទីស្រលាញ់ គឺប៉ាម៉ាក់របស់ខ្ញុំ។ពួកគេទាំងអស់មានបាបកម្មអ្វី បានជាពួកគាត់ស្លាប់ចោលខ្ញុំ តើការស្លាប់នៃក្រុមគ្រួសាររបស់ខ្ញុំជាទណ្ឌកម្មពីព្រះ ឬ ជាបាបកម្ម នៃក្រុម គ្រួសាររបស់ខ្ញុំ ។ បើខ្ញុំយករឿងចម្ងល់ទាំងនេះមកគិតក្នុងជីវិតកំពុងតែឯកោ ខ្ញុំហាក់បីដូចជាខ្ញុំមិនមែនជាមនុស្ស? គ្រួសារខ្ញុំ! ជាតិរបស់ខ្ញុំ! សុទ្ធតែជាអ្នកទទួលទណ្ឌកម្មពីព្រះមែនឬ? ការសង្ស័យ! ការរំពឹងទុក ការរង់ចាំ! ដើម្បីឆ្លើយតបទៅលើវិញ្ញាណក្ខន្ធក្រុមគ្រួសាររបស់ខ្ញុំ, ខ្ញុំមានអារម្មណ៍ដ៏ស្រ៊ាវស្រាញ តើខ្ញុំជាកូន, ជាបង, ជាប្អូនត្រូវធ្វើអ្វី ដើម្បីឆ្លើយតបជាកូនកតញ្ញូ? ខ្ញុំមានសង្ឃឹមពួ និង បានឃើញមានតុលាការយុត្តិធម៏មួយនៅក្នុងប្រទេសខ្ញុំ។ ខ្ញុំមានសេចក្តីសប្បាយរីករាយថា ប៉ាម៉ាក់របស់ខ្ញុំ បងប្អូនជាទីស្រលាញ់របស់ខ្ញុំ មានតុលាការមួយមករកយុត្តិធម៏ជូនពួកគាត់ ប៉ុន្តែ រាល់ការសង្ឃឹម ការសប្បាយរីករាយ ពីតុលាការនេះ វាក្លាយជារឿងចំអកឡកឡឺយទៅលើវិញ្ញាណក្ខន្ធប៉ាម៉ាក់របស់ខ្ញុំ និង បងប្អូនជនរួមជាតិជាទីស្រលាញ់របស់ខ្ញុំទៅវិញ! ខ្ញុំជាអ្នកទទួលទារុណកម្មក្នុងរបប ៣ឆ្នាំ ៨ខែ នេះ សូមស្នើតុលាការកូនកាត់នេះ កុំឲ្យវិញ្ញាណក្ខន្ធ ប៉ាម៉ាក់ និង ជនរួមជាតិរបស់ខ្ញុំធ្វើជាល្បែងនយោបាយរបស់អស់លោក។ វិញ្ញាណក្ខន្ធប៉ាម៉ាក់របស់ខ្ញុំ និង ជនរួមជាតិរបស់ខ្ញុំ ពួកគាត់ត្រូវការយុត្តិធម៏ពីតុលាការនេះ ឬ មួយពួកលោកគិតថាវិញ្ញាណក្ខន្ធជនរងគ្រោះទាំងនោះ ជាកាដូ ឬ រង្វាន់លើកទឹកចិត្តឲ្យពួកឃាតករបាតដៃប្រឡាក់ឈាមទាំងនោះរស់នៅយ៉ាងសប្បាយ! នៅពេលដំណើរការម្តងៗ នៃតុលាការកូនកាត់នេះ ខ្ញុំមិនដែលមានអារម្មណ៍រំពឹងថា ដំណើរទៅមានភាពយុត្តិធម៏ទេ។ រឿងខ្លះដំណើរទៅគ្រាន់តែជាឆាកឈុតដើម្បីចែកផលប្រយោជន៍គ្នាតែប៉ុណ្ណោះ ទាំងមន្ត្រីតុលាការខ្មែរ និង មន្ត្រីអង្គការសហប្រជាជាតិ មកដល់ម៉ោងនេះ។ លោក ធារ៉ា ជាជនរងគ្រោះ មិនសង្ឃឹមលើប្រព័ន្ធតុលាការនេះទេ ខ្ញុំសុំដកខ្លួនចេញពីដើមបណ្តឹងនេះ។ ខ្ញុំមិនអាចបើកភ្នែកមើលពីមន្ត្រីតុលាការនេះ យកវិញ្ញាណក្ខន្ធរបស់ ប៉ាម៉ាក់ និង ជនរួមជាតិរបស់ខ្ញុំ ជាល្បែងឈុតឆាកនយោបាយរបស់អស់លោកទាំងនេះទេ! យើងមិនអាចឈរមើលកំប្លុកកំប្លែងតុលាការកូនកាត់នេះបន្តទៀតទេ ហើយបើយើងនៅបន្ត ហាក់បីដូចជាយើងបានរួមដៃសម្លាប់លើវិញ្ញាណក្ខន្ធបងប្អូនជនរួមជាតិយើងម្តងទៀតអញ្ចឹង ។ ហើយខ្ញុំក៏រង់ចាំមើលពីដំណើរយុត្តាធិការរបស់អង្គការសហប្រជាជាតិ ដែលប្រជាជាតិលើពិភពលោក តែងតែសង្ឃឹមទៅលើ អង្គការសហប្រជាជាតិ ដែលជាអ្នកប្រកាន់នូវយុត្តិធម៏”។

ភ្នំពេញថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១១

KHMER ROUGE VICTIMS IN CAMBODIA
សមាគមជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅកម្ពុជា

ជ័យ ធារ៉ា

អនុប្រធានសមាគមជនរងគ្រោះក្នុងរបបខ្មែរក្រហមនៅកម្ពុជា